# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារ

កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារនេះ ត្រូវបានធ្វើឡើងនៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១ រវាង លោក **ហែម សក្កណា** កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០១០៩៣៧៤០៥ ដែលមានតួនាទី **នាយកគ្រប់គ្រងទូទៅ** និងជាតំណាងភាគីនិយោជក នៃក្រុមហ៊ុន **អិល&អិម បាសាក់រីវើរ ខូ អិលធីឌី** ដែលមានអាសយដ្ឋានស្ថិតនៅ **អាគារលេខ អិន២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ** ធ្វើជាមួយនិង ៖

- លោកស្រី **ទុន ស្រីត័ក្រ** កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០១០៦៨៥០៤៤ ដែលមានតួនាទីជាជំនួយការប្រធានផ្នែកគ្រប់គ្រងភោជនីយដ្ឋាន និងជាតំណាងភាគីនិយោជិកនៃក្រុមហ៊ុនខាងលើ។
- លោកស្រី **អ៊ុំ សៅឌីណា** កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០១១៣៦០៤៤៤ ដែលមានតួនាទីជាជំនួយការប្រធានផ្នែកគ្រប់គ្រងភោជនីយដ្ឋាន និងជាតំណាងភាគីនិយោជិកនៃក្រុមហ៊ុនខាងលើ។

ភាគីទាំងពីរបានធ្វើការព្រមព្រៀងគ្នាដូចខាងក្រោម៖

**១-<u>រយៈពេលនៃការព្យួរកិច្ចសន្យាការងារ ៖</u>**

ការព្យួរកិច្ចសន្យាការងារចាប់ពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ ចំនួនកម្មករសរុប ២៧០នាក់ ស្រី ១២៩នាក់ កម្មករព្យួរកិច្ចសន្យាការងារមាន ១៤នាក់ ស្រី ០នាក់ មូលហេតុដោយសារក្រុមហ៊ុនបានទទួលរងនូវផលប៉ះពាល់យ៉ាងអវិជ្ជមានលើផ្នែកហិរញ្ញវត្ថុ ដែលបង្កដោយវីរុស កូវីដ-១៩ ។

**២-<u>ប្រាក់ឧបត្ថម្ភកំឡុងពេលព្យួរកិច្ចសន្យាការងារ៖</u>**

ភាគីនិយោជក មិនមានផ្តល់ជាប្រាក់ឧបត្ថម្ភអ្វីឡើយ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ ។

ភាគីនិយោជិត មិនទាមទារប្រាក់ឧបត្ថម្ភអ្វីឡើយ ពីនិយោជក ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ ។

**៣-<u>កាលបរិច្ឆេទចូលបម្រើការងារវិញ ៖</u>**

បុគ្គលិកនិយោជិកទាំងអស់ត្រូវត្រឡប់ចូលមកបម្រើការងារវិញ បន្ទាប់ពីរយៈពេលព្យួរកិច្ចសន្យាការងារនេះត្រូវបានបញ្ចប់។

កិច្ចសន្យានេះត្រូវបានធ្វើឡើងជាពីរ(០២)ច្បាប់ និងមានតម្លៃស្មើគ្នាចំពោះមុខច្បាប់ ដែលសម្រាប់ភាគីនីមួយៗទុកម្នាក់មួយ(០១)ច្បាប់។ ភាគីទាំងពីរបានអាន ព្រមព្រៀងគ្នា និងបានផ្តិតមេដៃ ដើម្បីជាសាក្ខីភាព។

រាជធានីភ្នំពេញថ្ងៃទី ១៣ ខែមេសា ឆ្នាំ២០២១

**តំណាងប្រតិភូពេញសិទ្ធ**

**លោកស្រី ទុន ស្រីត័ក្រ**

**លោកស្រី អ៊ុំ សៅឌីណា**

**តំណាងភាគីនិយោជិត**

**លោក ហែម សក្កណា**